មកពីមូលហេតុនេះហើយ ដែលមនុស្សជាច្រើនគ្មានសង្ឃឹមសំរាប់ព្រលឹងវិញ្ញាណរបស់គេទាល់តែសោះ ។ គេតែងតែគិតថា គេត្រូវតែសង្គ្រោះខ្លួនដោយខ្លួនឯង តែគេមិនអាចសង្គ្រោះខ្លួនបានទេ

ប៉ុន្តែមានដំណឹងល្អម្យ៉ាង គឺជាព្រះយេស៊ូវអាចសង្គ្រោះអ្នកបាន ព្រះគម្ពីរបានប្រាប់យើងថា ព្រះយេស៊ូវគឺជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត ។ ទ្រង់ស្រឡាញ់អ្នក ទ្រង់បានសុគតនៅលើឈើឆ្កាង

ដើម្បីទទួលទណ្ឌកម្មនៃអំពើបាប ជំនួសយើងរាល់គ្នា ទ្រង់បានរស់ពីសុគតឡើងវិញ ដើម្បីប្រទានជ័យជំនះលើសេចក្តីស្លាប់ដល់យើងរាល់គ្នា

ទ្រង់ចង់អត់ទោសបាបរបស់អ្នក ដើម្បីឱ្យអ្នកអាចឡើងទៅស្ថានសួគ៌នៅថ្ងៃណាដែលអ្នកស្លាប់ទៅ ។

បើសិនជាអ្នកចាប់អារម្មណ៏ ហើយចង់យល់ថែមទៀត អំពីដំណឹងល្អរបស់ព្រះយេស៊ូវ សូមបំពេញកាតនៅខិតប័ណ្ណនេះ ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងគ្នា យើងចង់តែជួយនាំឱ្យអ្នកស្គាល់ព្រះពិតតែមួយ គឺជាព្រះយេស៊ូវគ្រីស្ទ ។

ការិយាល័យ សំរាប់ទាក់ទង
ប្រអប់ ប្រៃសណីយ៍ ២៥០៦
ភ្នំពេញ ៣

# កីឡាករទាំងអស់ចង់ឈ្នះ!!!



## កីឡាករជាច្រើនបាន
## មកពីបណ្តាខេត្តនានា
## ដើម្បីចូលរួមការប្រណាំងទូក
## ពីព្រោះគេចង់បានចំណាត់ថ្នាក់លេខ១

នេះគឺជារឿងពីក្រុមប្រណាំងទូកមួយក្រុម ដែលចង់ឈ្នះលើទូកទាំងអស់ ដោយវិធីណាក៏ដោយឱ្យតែបានឈ្នះ នៅពេលដែលការប្រណាំងទូកតង់ទីមួយបានមកដល់ហើយ ពួកគេក៏បានបញ្ចេញកំលាំងអស់ពីសេចក្តីព្យាយាមរបស់ពួកគេ ប៉ុន្តែនៅពេលដែលការប្រណាំងទូកបាន ត្រូវបញ្ចប់ហើយ ទោះបីជាពួកគេបានព្យាយាម អស់ពីកំលាំងកាយកំលាំងចិត្តយ៉ាងណាក៏ដោយ គង់តែវានៅតែមិនល្អមទេ ។ ដូច្នេះនៅពេលតង់ទី២ បានចាប់ផ្តើម គេក៏បានរៀបចំឧបាយកលមួយ គឺពួកគេបានដាក់មាស៊ីនដ៏តូចមួយនៅក្នុងទូក របស់ពួកគេ ដោយគ្មាននរណាម្នាក់អាចមើលឃើញឡើយ ប៉ុន្តែគណៈកម្មការបានឮសំលេងមាស៊ីនមួយនោះ ហើយគាត់បានប្រាប់គេថា គេមិនអាចចូលរួមការប្រកួតបានទេ ។ គាត់បាននិយាយថែមទៀតថា " សូម្បីតែបងប្អូន បានព្យាយាមអស់ពីចិត្តក៏ដោយ ក៏ប៉ុន្តែបងប្អូនមិនបានគោរពក្នុងលក្ខ័នណ្ឌនៃការប្រកួត ដូច្នេះ អ្នកទាំងអស់គ្នា គ្មានសិទ្ធអាចទទួលជ័យលាភីបានទេ ។ ដូច្នេះ អ្នកអុំទូកមួយក្រុមនោះ បានត្រឡប់ទៅផ្ទះរបស់ពួកគេវិញ ដោយការសោយចិត្ត ពីព្រោះគេដឹងថា គេគ្មានសង្ឃឹមទាល់តែសោះ សំរាប់ការយកឈ្នះ ។

នេះគឺជារឿងសោកស្តាយមែនទែន ប៉ុន្តែជាការពិតណាស់ រឿងនេះមិនសូវខុសពីមនុស្ស ដែលចង់ឡើងទៅស្ថានសួគ៍ទេ ពីព្រោះកីឡាករមួយក្រុមនោះ បានព្យាយាមចង់ឱ្យបានឈ្នះ ដោយសមត្ថភាពរបស់ខ្លួនគេ យ៉ាងដូច្នេះហើយមនុស្សមួយចំនួន ក៏ចង់ព្យាយាមរកផ្លូវទៅស្ថានសួគ៌ ដោយសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេដែរ ។ គេចូលវិហារ ដើម្បីបួងសួង អធិស្ឋាន នឹងថ្វាយបង្គំព្រះ គេព្យាយាមធ្វើការល្អ ដោយធ្វើបុណ្យច្រើន ហើយគេសង្ឃឹមថា នៅពេលដែលជីវិតរបស់គេបានចប់ហើយ គេគិតថា ការធ្វើបុណ្យនឹងការធ្វើការល្អរបស់គេ នឹងជួយឱ្យគេបានទទួលរង្វាន់ជាការឡើងទៅស្ថានសួគ៌ ប៉ុន្តែ ដូចជាអ្នកអុំទូកមួយក្រុមនោះ ដែលមិនអាចចូលរួមការប្រកួតបាន ដោយគេលេងខូច យ៉ាងដូច្នេះព្រះគម្ពីរនិយាយថា មនុស្សទាំងអស់មិនអាចចូលទៅក្នុងស្ថានសួគ៌បានទេ ដោយព្រោះអំពើបាបរបស់គេដែរ ។ ទោះបើយើងខំព្យាយាមលាក់អំពើបាបរបស់យើង នោះយើងនៅតែមិនអាចលាក់អំពើបាបរបស់យើងពីព្រះបានទេ ព្រះគម្ពីរបានប្រាប់ឱ្យយើងដឹងថា មនុស្សយើងទាំងអស់បានធ្វើបាប ហើយនឹងគ្មាននរណាម្នាក់សុចរិតសោះ ដោយព្រោះអំពើបាបរបស់យើង ព្រះដែលទ្រង់ជាបរិសុទ្ធ ទ្រង់មិនព្រមអនុញ្ញាតឱ្យយើងអាចចូលស្ថានសួគ៌បានឡើយ ជាការពិតណាស់ ព្រះទ្រង់មានបន្ទូលថា អំពើបាបរបស់មនុស្សទាំងអស់ត្រូវទទួលទណ្ឌកម្ម ។ ដូចជាកីឡាករមួយក្រុមនោះបានត្រឡប់ទៅផ្ទះរបស់គេ ដោយអស់សង្ឃឹម នោះមានមនុស្សជាច្រើន ដែលមានអារម្មណ៍យ៉ាងដូច្នេះដែរ អំពីជីវិតរបស់គេ មនុស្សជាច្រើនគេគិតថា គ្មានសង្ឃឹមសោះ ដើម្បីទទួលការអត់ទោសចំពោះអំពើបាបរបស់គេ ហើយថែមទៀតគេគិតថា គ្មានសង្ឃឹមសោះ ដើម្បីឱ្យបានជីវិតអស់កល្បជានិច្ច សូម្បីតែសាសនាព្រះពុទ្ធក៏បង្រៀនដែរថា បុណ្យដែលយើងធ្វើមិនអាចលុបបាបចេញបានទេ (បាបជាបាប បុណ្យជាបុណ្យ) ហើយសាសនាព្រះពុទ្ធបានបង្រៀនទៀតថា យើងត្រូវតែសង្គ្រោះខ្លួនដោយខ្លួនឯង ( ខ្លួនទីពឹងខ្លួន ) ។